# កម្មវិធីនេះរៀបរៀង ដោយអង្គការជារ៉ាវី នៃសាន់ ប្រចាំកម្ពុជា តំបន់អាស៊ី។

## មេរៀនបច្ចេកទេសចិញ្ចឹមពូជមាន់ខ្មែរ

(ចំណុចទី១) សង្ខេប អំពីពូជមាន់នៅក្នុងស្រុក មានច្រើនប្រភេទសម្រាប់នៅក្នុង ប្រទេសកម្ពុជាយើងបច្ចុប្បន្ន។

សូមណែនាំខ្លះៗ អំពីពូជមាន់ដែលមានប្រភេទខុសៗគ្នាមានដូចខាងក្រោម សម្រាប់មាន់ខ្មែរមានពូជមាន់ ក្រញ៉ាស់ មាន់ថៃ មាន់ខ្មៅ មាន់ស្លួយ (មាន់កណ្តូង អត់កន្ទុយ) មាន់ប្រភេទ

កណ្តាល មាន់ថៃស និងមាន់ព្រៃ។

សូមមើលតារាងបញ្ជាក់អំពីទម្ងន់រវាងពូជមាន់និមួយៗនៅខាងលើនេះមានដូចខាក្រោនេះ។

| លរ | ប្រភេទពូជមាន់ | ប្រភេទទម្ងន់ |
|---|---|---|
| ១ | មាន់ស្លួយ | ជិត៤គីឡូ |
| ២ | មាន់ធំកណ្តាល | ៣គីឡូលើស |
| ៣ | មាន់កណ្តូង | ជិត៤គីឡូ |
| ៤ | មាន់ក្រញ៉ាស់ | ចាប់ពី២ទៅ៣គីឡូ |
| ៥ | មាន់ខ្មៅទាំងសាច់ | ចាប់ពី២ទៅ៣គីឡូ |
| ៦ | មាន់ថៃ | ចាប់ពី៣ឬលើសពី៣គីឡូក្រោម |
| ៧ | មាន់សំឡី | ចាប់ពី១គីឡូឬលើស |

តារាងបញ្ជាក់ពី រយះពេលនៃការចិញ្ចឹម ចាប់ពីសូន្យថ្ងៃ ដល់ពេលមាន់ពេញវ័យសម្រាប់មាន់មេ និងឈ្មោល។

| លរ | ពូជមាន់ | រយះពេលនៃការចិញ្ចឹម |
|---|---|---|
| ១ | មាន់ស្លួយ | ពីសូន្យថ្ងៃដល់ អាយុ៧ខែ(មេពេញវ័យ)<br>ពីសូន្យថ្ងៃដល់ អាយុ១០ខែ(ឈ្មោលពេញវ័យ) |
| ២ | មាន់កណ្តូង | ពីសូន្យថ្ងៃដល់ អាយុ៧ខែ(មេពេញវ័យ) |

| | | |
|---|---|---|
| | | ពីសូនថ្ងៃដល់ អាយុ១០ខែ(ឈ្មោលពេញវ័យ) |
| ៣ | ប្រភេទមាន់កណ្ដាល | ពីសូនថ្ងៃដល់ អាយុ៧ខែ(មេពេញវ័យ)<br>ពីសូនថ្ងៃដល់ អាយុ១០ខែ(ឈ្មោលពេញវ័យ) |
| ៤ | មាន់ក្រញ៉ាស់ | ពីសូនថ្ងៃដល់ អាយុ៧ខែ(មេពេញវ័យ)<br>ពីសូនថ្ងៃដល់ អាយុ១០ខែ(ឈ្មោលពេញវ័យ) |
| ៥ | មាន់ខ្មៅទាំងសាស់ | ពីសូនថ្ងៃដល់ អាយុ៧ខែ(មេពេញវ័យ)<br>ពីសូនថ្ងៃដល់ អាយុ១០ខែ(ឈ្មោលពេញវ័យ) |
| ៦ | មាន់ថៃ | ពីសូនថ្ងៃដល់ អាយុ៧ខែ(មេពេញវ័យ)<br>ពីសូនថ្ងៃដល់ អាយុ១០ខែ(ឈ្មោលពេញវ័យ) |
| ៧ | មាន់សំឡី | ពីសូនថ្ងៃដល់ អាយុ៧ខែ(មេពេញវ័យ)<br>ពីសូនថ្ងៃដល់ អាយុ១០ខែ(ឈ្មោលពេញវ័យ) |

## (ចំណុចទី២) វិធីនិងបច្ចេកទេសចិញ្ចឹមមាន់ខ្មែរ

### វិធីការជ្រើសរើសពូជ(សម្រាប់មាន់មេ)

១«សុខភាពល្អកម្លាំងមាំមួន(ស្អួយ និងដូង)

២«ពូជធំល្អមានមាឌមាំទាំ

៣«ចេះថែរក្សាពងនិងកូនបានល្អ

៤«ត្រគាកសាយពង

### សម្រាប់មាន់ឈ្មោល

១«សុខភាពល្អកម្លាំងមាំមួន(មិនជាន់ឈាម)

២«មានមាឌធំនិងមាំខ្ពស់

៣« មានជើងធំៗហើយមាំ

៤«មានជំពុះមាំល្អអាចស៊ីចំណីបានច្រើន

### សម្រាប់កូនមាន់ធ្លាក់ពីសំបុក

១«បំបែកកូនទាំងអស់ចេញពីមេដាក់ក្រុង
ក្នុងទ្រុងដាច់ដោយឡែកនិងដាក់មុងឲ្យដេក ប៉ុន្តែត្រូវប្រើអំពូលភ្លើង
ពណ៌ក្រហមតូចៗ ដើម្បីបំប៉នកំដៅ
១ខែដើម្បីឲ្យសារីរាង្គកូនមាន់មានការលូតលាស់ធំឋិតបានល្អ។

២«ឲ្យចំណីប្រភេទបំប៉ន (ជាផលិផលសម្រេចពីរោងចក្រឬក៏កែឆ្នៃ)

៣«មានទឹកផឹកនិងទឹកអ៊ីអ៊ុីមជាប្រចាំការពារជម្ងឺ

៤«តាមដានជាប្រចាំ បើមានកូនមាន់ណាអន់ ឬសំកុកឈឺ
ត្រូវបំបែកចេញពីហ្វូងយកទៅដាក់ដោយឡែកពីគេ
ជៀសវាងការឆ្លងជម្ងឺពីមួយទៅមួយ។

៣«ការផ្សំចំណីពិសេស សម្រាប់កូនមាន់និងមាន់ធំ

| លរ | ប្រភេទមុខវត្ថុលាយផ្សំ(ប្រភេទស្អុត្រូវកិនជាមុន) | ចំនន្ទននិងទម្ងន់ |
|---|---|---|
| ១ | ចុងអង្ករ | ៤គីឡូ |
| ២ | ពោតក្រហម | ២០គីឡូ |
| ៣ | មើមដំឡូងមី | ៤គីឡូ |
| ៤ | សណ្ដែកបាយ និងសៀង | ៤គីឡូ |
| ៥ | កន្ទក់ | ៧គីឡូ |
| ៦ | កូនត្រីក្រៀប្រលាក់អំបិល | ២ឬ៣គីឡូ |
| ៧ | សំបកខ្យង ង៉ាវ លៀស(កម្លោច ហើយបុកម៉ត់ៗ) | ១គីឡូ កន្លះ |
| ៨ | អំបិលគ្រួស(លីងផង) | ១កំប៉ុងអង្ករ |
| ៩ | ទ្រួយនិងស្លឹកន្ទំថេតស្ងួត | ២គីឡូក្រោម |
| ១១ | កញ្ជែតបឹង(ក្រៀម) | ២គីឡូ |
| ១២ | ត្រកួនស(ដាំ)យកក្រៀម | ៣គីឡូ |
| ១៣ | អង្កាមកិនឲ្យម៉ត់ | ៣គីឡូ |
| ១៤ | ដីដំបកខ្ជួយតាមវាលស្រែលីង | ១គីឡូកន្លះ |

វិធីលាយផ្សំ មុខវត្ថុលាយផ្សំខាលើទាំអស់នោះ
បន្ទាប់ពីបានកិនឬបុកខ្ទិចអស់រួចរាល់អស់ហើយ
ត្រូវច្របល់ចូលគ្នាឲ្យសព្វ
រួចហើយច្រកទុកដាក់ក្នុងការ៉ុងឲ្យបានត្រិមត្រូវ។

(ចំណុចទី៣) ការផ្តល់ចំណីស្រស់សម្រាប់បំប៉នមាន់ធំ

១«មានស្រូវស្រោលឬធូន់(កន្លះគ)

២«មានដើមចេកផ្ងានិងកន្ទក់លាយឲ្យស៊ី (៣គ)

៣«មានកូនត្រីជម្ពូជាតិ(ក្រៀមប្រឡាក់អំបិលឡែមៗកិនផង)(៤ខាំ)

៤«មានត្រកួនដាំឬស្រែ (៤ខាំ)

៥«មានពោតក្រហម(២គ)

៦«ចុងអង្ករ (២កំប៉ុង)

៧«អំបិគ្រួសលីង ២ស្លាបព្រា

៨«វត្ថុខាងលើនេះ បុកហើយត្រូវច្របល់ចូលគ្នាឲ្យសព្វ
ទើបលាយឲ្យសត្វស៊ី។

## (ចំណុចទី៤)ការផ្តល់ទឹកសម្រាប់មាន់ផឹក

១«មានទឹកស្អាតគ្មានសារធាតុគីមី តាមស្ទឹង បឹងឬបួ អូរ ស្រះ

២«ហាមប្រើប្រាស់ប្រភពទឹកដែលយើងមិនដឹងភូមិសាស្ត្រច្បាស់លាស់
យកមកប្រើប្រាស់។

៣«មានស្នូកទឹកត្រឹមត្រូវស្អាតល្អ

## (ចំណុចទី៥)ការបន្តពូជ(ជៀសវាងការជាន់ឈាមគ្នា)

១«មាន់ឈ្មោលត្រូវជ្រើសរើស ពីទីកន្លែងផ្សេងៗគ្នា

២«មាន់ញីក៏ដូចពូជមាន់មឈ្មោលដែរ
ត្រូជ្រើសរើសពីទីកន្លែងផ្សេងៗគ្នាផងដែរ
ជៀសវាងយកពូជជាមួយគ្នា។

៣«ហាមមិនឲ្យ អាឈ្មោលជាន់កូខ្លួនឯង និងបន្តពីកូនទៅកូនគ្នាវា
បញ្ហា នាំឲ្យមាន់ទាំងអស់នោះមានជម្ងឺច្រើន
ហើយភាគច្រើនគឺក្រិនស្កមរីងរៃ និងមិនធំបិតលូតលាស់ទៅមុខ។ល។

## (ចំណុចទី៦)បច្ចេកទេសសង់រោង

១«ត្រូវជ្រើសរើសដីទីទួលផុតពីទឹកលិច ដើម្បីសុខភាពសត្វ

២«សង់ឲ្យផុតពីកន្លែងព្រៃស្អុក(ការពារសត្វពោះពីសខាំ)

៤«ទីតាំងសាងសង់ ដាក់ឲ្យចំបណ្តោយថ្ងៃ
ដើម្បីឲ្យពន្លឺថ្ងៃសម្បូណ៌ទៅដោយវីតាមីនឌី
ជួយទៅកាត់បន្ថយមេរោគខ្លះនៅតាងដីនិងរោង
និងបរិវេណជុំញរបស់រោង។

៥«ខ្នាតសាងសង់រោង  ដោយសង់ទទឹង ស្មើ ២ម៉ែត្រ៧តឹក
ចំណែកបណ្តោយស្មើ ៥ម៉ែត្រ រីឯកំពស់មេដំបូលស្មើ ២ម៉ែត្រ ៥តឹក
រីឯកំពស់ជើងរៀងស្មើ ២ម៉ែត្រ ។

សម្រាប់ដំបូលអាចប្រក់ពីស័ង្កះសី ឬស្បោក៏បាន
ចំណែកក្រោងរោង អាចសង់ពីឈើ ឬដែក ថ្មនិស៊ីម៉ង់ខ្លះក្រាលបាត
ចំណែករបាជញ្ជាំងអាចសង់ពីឫស្សីឬឈើ
និងសំណាញ់នីលុងសម្រាប់ពាត់ទ្រុងជំវិញព្រមទាំងចងការពាមុះផង
និងថ្មើសម្រាប់ដេកទៀតផង។

ផ្នែកជម្រៅជើងសសរ ស្មើ៣ៗតឹក ការសាងសង់ខ្នាតខាងលើនេះ
គឺមានសុវត្ថភាពក្នុងការមើលថែទាំងប្រចាំថ្ងៃ
ជិះវាងការដើរជល់ឬប៉ះដង្គិចក្បាល ឬភ្នែក។

សូមបញ្ជាក់ ទំហំរោងខាងលើនេះ   អាចដាក់កូនមាន់បាន
ចាប់ពី២០០ទៅ៣០០ក្បាល។

## (ចំណុចទី៧)ការរៀបចំទីតាំងមាន់ពង

១«ដាក់សំបុកឲបានត្រិត្រូវជៀសវាងធ្លាក់ពងបែក

២«មានថ្នាំការពារសត្វស្រមើុល មិនឲ្យខាំសត្វ

៣«ឧស្សាតាមដានមើល មេផ្សេងៗឡើពងជាន់លើគ្នា

៤«ឧស្សាប្រជាវពងវាផង
ពីថ្ងៃម្តងដើម្បីឲ្យពងវាងាយឆាប់ញាស់បានស្រុះល្អ។

## (ចំណុចទី៨)វិធីសាស្រ្តការថែទាំ

១«មានចំណីគ្រប់គ្រាន់

២«មានថ្នាំការពារដោយធ្មជាតិឬពេទ្យ

៣«មានទឹកស្អាត និងបោសសំអាតទ្រុង

៤«ទ្រុងមានសំណាញ់ និងមុងការពារមុះ

៥«មិនទិញសត្វឈឺពីកន្លែងផ្សេងៗមកហូបនៅផ្ទះ

៦«មានការតាមដានជាប្រចាំ(បើមានសត្វឈឺត្រូវបំបែក)

៧«ចេះផ្ទេបទពិសោធន៏ដល់ក្រុមគ្រួសារដើម្បីថែទាំ

៨«មានជម្ងឺកាចសាហាវមិនត្រូវ យកសត្វមកហូប ត្រូវហាមក្រុមគ្រួសារឲ្យបានដឹងគ្រប់ៗគ្នា។

៩«មានជម្ងឺកាចសាហាវ ហាមកុំប៉ះពាល់សត្វ
និងរាយការណ៍ប្រាប់ដល់ពេទ្យសត្វភូមិ។

១០«ទ្រុងឧស្សាហបាចផេះឬកំបោសដើម្បីបណ្តេញមេរោគ

(ចំណុចទី១១)ការកត់សំគាល់រោគសញ្ញាសត្វមាន់

ទី១«មានជម្ងឺអុតលើមុខសត្វមាន់

ទី២«មានជម្ងឺផ្តាស់សាយតូចធំ

ទី៣«មានអាសន្នរោគ

ទី៤«សត្វមានជម្ងឺស្លេកស្លាំង(ដោយសាសត្វព្រូនក្នុងពោះ)

(ចំណុចទី១២)ការព្យាបាល ជម្ងឺសត្វត្រូវតាមរោគសញ្ញា

ទី១«មានជម្ងឺអុតលើមុខសត្វ

ទី២«មានជម្ងឺផ្តាស់សាយតូចធំ

ទី៣«មានអាសន្នរោគ

ទី៤«សត្វមានជម្ងឺស្លេកស្លាំង(ដោយសាសត្វព្រូនក្នុងពោះ)

៥«សត្វឧស្សាឈរសំកុក មិនខ្លៀវក្លា(សត្វកំពុងមានបញ្ហា)